# សេចក្តីសង្ខេបសំខាន់ៗ

សត្វផ្សោតក្បាលត្រឡោកមានរស់នៅក្នុងទន្លេមេគង្គនៃប្រទេសកម្ពុជាចាប់ពីខេត្តក្រចេះបន្តទៅល្បាក់ខោនស្ថិតនៅប៉ែកខាងត្បូងនៃប្រទេសឡាវ។ កាលពីមុន សត្វផ្សោតប្រភេទនេះក៏ធ្លាប់បានប្រទះឃើញនៅតាមចរន្តទឹកខាងក្រោមនៃទន្លេមេគង្គក្នុងប្រទេសវៀតណាម និងក្នុងបឹងទន្លេសាបនៃប្រទេសកម្ពុជាផងដែរ។ បច្ចុប្បន្ននេះ សត្វផ្សោតក្បាលត្រឡោកពុំមានវត្តមាននៅគ្រប់ទីកន្លែងដែលជាដែនជម្រករបស់វាពីមុនឡើយ ហើយគេគិតថា ចំនួនសរុបរបស់វាមានកម្រិតតិចតួចបើប្រៀបធៀបទៅនឹងចំនួនសរុបដែលធ្លាប់មានពីមុនមក។ ប៉ុន្តែមកទល់ពេលនេះ គេនៅតែមិនដឹងច្បាស់ថា សត្វផ្សោតសរុបប៉ុន្មានក្បាលនៅរស់រានមានជីវិត ហើយចំនួនសរុបរបស់វានៅតែបន្តធ្លាក់ចុះ ឬក៏អត់នោះដែរ។

ចាប់តាំងពីដើមឆ្នាំ២០០៧ គម្រោងអភិរក្សសត្វផ្សោតទន្លេមេគង្គកម្ពុជាដែលជាគម្រោងសហប្រតិបត្តិការរវាងរដ្ឋបាលជលផល និងអង្គការ WWF កម្ពុជា បាននិងកំពុងធ្វើការសិក្សាអង្កេតលើការប៉ាន់ប្រមាណចំនួនសរុបនៃសត្វផ្សោតនៅក្នុងទន្លេមេគង្គ ដោយប្រើប្រាស់វិធីសាស្ត្រថតរូបភាពគ្រប់សត្វផ្សោតទាំងអស់នៅក្នុងទន្លេមេគង្គ។ ការប៉ាន់ប្រមាណពីភាពសម្បូរណ៍បែប និងកត្តាផ្សេងៗដែលពាក់ពន្ធ័នឹងការប៉ាន់ប្រមាណលើចំនួនសរុប (ឧទា: ចំនួនសរុបសត្វផ្សោតដែលនៅរស់ និងការកត់ត្រាបន្ថែមវត្តមានរបស់សត្វផ្សោតថ្មី) ជួបការលំបាកច្រើន ពីព្រោះការតាមរាប់សត្វផ្សោតនៅតាមជម្រកក្នុងធម្មជាតិមិនមែនជាការងាយស្រួលនោះឡើយ ហើយការរាប់សត្វផ្សោតទាំងនោះពឹងអាស្រ័យលើស្លាកសំគាល់លើដងខ្លួនរបស់វា (ឧទា: ស្នាមរលាត់លើស្បែក និងទម្រង់ផ្សេងៗរបស់ព្រុយខ្នងជាដើម) ហើយសត្វផ្សោតមួយចំនួនទៀតពុំមានចំនុចសំគាល់ច្បាស់លាស់នៅលើដងខ្លួនឡើយ។ វិធីសាស្ត្រវិភាគទិន្នន័យចុងក្រោយគេ (Analytical Advances) នាពេលនេះអាចឲ្យយើងប្រើប្រាស់កាន់តែប្រសើរនូវរាល់ទិន្នន័យទាំងអស់ប្រមូលបានតាមរយៈការអង្កេតទាំងលើសត្វផ្សោតដែលមានចំនុចសំគាល់ និងមិនមានចំនុចសំគាល់លើដងខ្លួនវា។ យើងបានប្រើប្រាស់វិធីសាស្ត្រវិភាគទំនើបទាំងនេះធ្វើការប៉ាន់ប្រមាណពីចំនួនសត្វផ្សោតដែលនៅរស់ក្នុងអំឡុងពេលអង្កេត១១លើកធ្វើឡើងក្នុងរយៈឆ្នាំ២០០៧-២០១០ ដើម្បីវាយតម្លៃពីបម្រែបម្រួលចំនួនសរុប និងប្រសិទ្ធិភាពរបស់វិធីសាស្ត្រអង្កេតក្នុងគោលបំណងតាមដានពីភាពប្រែប្រួលចំនួនសរុបនេះ។ ការវិភាគទាំងអស់ប្រើប្រាស់វិធីសាស្ត្រ Mark-Resight ដើម្បីបញ្ចូលទិន្នន័យរូបថតសត្វផ្សោតដែលស្គាល់ភិនភាគ និងថតបានសាជាថ្មីក្នុងគោលបំណងធ្វើការប៉ាន់ប្រមាណពីចំនួនសត្វផ្សោតដែលនៅរស់ និងស្ថានភាពអន្តរកាល។ យើងក៏ប្រើប្រាស់វិធីសាស្ត្រ Reverse Time ពិនិត្យមើលទិន្នន័យប្រមូលបាននាពេលកន្លងមកដើម្បីធ្វើការប៉ាន់ប្រមាណពីចំនួនសរុប។ ការវិភាគទាំងអស់ធ្វើឡើងដោយប្រើកម្មវិធី Mark ( Solfware Programme Mark )។

លទ្ធផលអង្កេតចន្លោះឆ្នាំ២០០៧-២០១០ បានបង្ហាញឲ្យដឹងថា ចំនួនប៉ាន់ប្រមាណសរុបនៃសត្វផ្សោតពេញវ័យមាន ៨៥ក្បាល (ដោយរាប់បញ្ចូលទាំងសត្វផ្សោតដែលមានចំនុចសំគាល់ និងមិនមានចំនុចសំគាល់លើដងខ្លួន)។ យើងសំគាល់ឃើញថា តួលេខនេះខ្ពស់ជាងតួលេខដែលទទួលបានពីការសិក្សាអង្កេតចំនួនពីរដង លើកទីមួយក្នុងឆ្នាំ២០០៧ ដែលមានចំនួនតែ ៧១ក្បាល (នៅចន្លោះពី ៦៦-៨៦ និងកម្រិតជឿជាក់មានដល់ទៅ ៩៥%)។ យើងជឿជាក់ថា ការប៉ាន់ប្រមាណនេះមានកម្រិតខ្ពស់ជាងចំនួនសរុបដែលទទួលបានក្នុងឆ្នាំ២០០៧ ពីព្រោះយើងបានវិភាគបណ្តុំទិន្នន័យដែលមានបរិមាណច្រើនជាងមុន ហើយបានប្រើប្រាស់វិធី

សាស្ត្រទំនើបចុងក្រោយបង្អស់ដែលវិធីសាស្ត្រនេះមិនទាន់មាននៅឡើយកាលពីឆ្នាំ២០០៧។ សូមធ្វើការកត់សំគាល់ថា បើទោះជាចំនួនប៉ាន់ប្រមាណនេះមានកម្រិតខ្ពស់ជាងចំនួនប៉ាន់ប្រមាណនៅក្នុងឆ្នាំ២០០៧ ក៏ដោយក៏កម្រិតខ្ពស់ជាងនេះមិនបានបង្ហាញពីការកើនឡើងនៃចំនួនសត្វផ្សោតក្នុងចន្លោះឆ្នាំ២០០៧-២០១០ នោះឡើយ។ ផ្ទុយទៅវិញ តួលេខនៃកំណើនចំនួនប៉ាន់ប្រមាណសរុប (០.៩៧៨) បង្ហាញឲ្យឃើញពីការធ្លាក់ចុះក្នុងកម្រិតទាបនៃសត្វផ្សោតដែលបានស្គាល់ភិនភាគ (សត្វផ្សោតដែលបានកត់ត្រានៅក្នុងបញ្ជីទិន្នន័យ) ហើយចំនួនប៉ាន់ប្រមាណសរុប៨៥ក្បាលនៅចន្លោះឆ្នាំ២០០៧-២០១០ តិចជាងចំនួន១១៥ក្បាលដែលប៉ាន់ប្រមាណដោយអ្នកស្រាវជ្រាវមុនៗនៅចន្លោះឆ្នាំ២០០៤-២០០៥។ យើងក៏ពិនិត្យឃើញដែរថា កំណត់ត្រាថ្មីរបស់សត្វផ្សោតពេញវ័យដែលបានមកពីការវិវត្តន៍នៃសត្វផ្សោតវ័យជំទង់មានកម្រិតទាបបំផុត ហើយយើងជឿជាក់ថា កម្រិតទាបបំផុតនៃការវិវត្តន៍នេះ បង្ហាញពីការធ្លាក់ចុះជាបណ្តើរៗនៃចំនួនសរុបរបស់សត្វផ្សោត ពីព្រោះពុំមានសត្វផ្សោតថ្មីក្នុងចំនួនគ្រប់គ្រាន់ត្រូវបានដាក់ជំនួសសត្វផ្សោតដែលបានបាត់បង់នោះឡើយ។ ការវិភាគស្ថិតិដោយប្រើវិធីសាស្ត្រ Statistical Power បានឲ្យដឹងថា ការសិក្សាអង្កេតលើចំនួនសរុបសត្វផ្សោតនាពេលបច្ចុប្បន្នរកឃើញពីការធ្លាក់ចុះ៣%នៃចំនួនសរុបប្រចាំឆ្នាំក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ។

យើងសន្និដ្ឋានថា បើពុំមានវិធានការអភិរក្សសមស្របទេនោះ វានឹងមានការគំរាមកំហែងដែលនាំឲ្យសត្វផ្សោតនឹងត្រូវបាត់បង់ពីទន្លេមេគង្គ។ សត្វផ្សោតដែលនៅមានចំនួនតិចត្រង់ទីជម្រកតាមបណ្តោយព្រំប្រទល់កម្ពុជា-ឡាវកំពុងទទួលរងនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ពីព្រោះចំនួនសរុបនៅសេសសល់ប្រមាណ ពី៧ទៅ៨ក្បាលប៉ុណ្ណោះ។ បើទោះជាសកម្មភាពគ្រប់គ្រងនាពេលបច្ចុប្បន្ននេះ (ឧទាៈ កិច្ចការពារដោយច្បាប់ ការបញ្ឈប់ការនេសាទខុសច្បាប់ ការហាមឃាត់លើការប្រើប្រាស់មង) ទំនងជាជួយដល់សត្វផ្សោតក៏ដោយក៏យើងជឿជាក់ថា ការកំណត់ឲ្យបានច្បាស់លាស់លើគោលដៅស្តារចំនួនសរុបឡើងវិញ និងចំណាត់ការលើសកម្មភាពសំខាន់ៗដែលរួមចំណែកជួយសង្គ្រោះសត្វផ្សោត គឺជាភាពចាំបាច់ដើម្បីការពារសត្វផ្សោតក្បាលត្រឡោកកុំឲ្យផុតពូជពីទន្លេមេគង្គ។